# របាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ ២០១៤ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ

I. **ស្ថានភាពការងាររបស់មន្ទីរ ÷**

1. **ការិយាល័យ រដ្ឋបាល និងកិច្ចការទូទៅ ÷**

❖ **ស្ថានភាពបុគ្គលិកមន្ត្រីរាជការក្នុងមន្ទីរ**

ការងារគ្រប់គ្រងនិងដឹកនាំមន្ទីរមានថ្នាក់ដឹកនាំចំនួន ៣ រូប (ប្រធានមន្ទីរ និងអនុប្រធានមន្ទីរ ០២ រូប) និងមានការិយាល័យជំនាញចំនួន ១០ ការិយាល័យ ÷

១- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ
២- ការិយាល័យផែនការ-ស្ថិតិ
៣- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
៤- ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ
៥- ការិយាល័យអភិវឌ្ឍន៍សហគមន៍
៦- ការិយាល័យផ្គត់ផ្គង់ទឹកជនបទ
៧- ការិយាល័យថែទាំសុខភាពជនបទ
៨- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
៩- ការិយាល័យផ្លូវជនបទ
១០- ការិយាល័យអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងមានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកចំនួន ០៧ និងក្រុងចំនួន ០១។

1.1. **ចំនួនមន្ត្រីរាជការ**

- សរុប ÷ ២៦នាក់
  - ប្រុស ÷ ២២នាក់
  - ស្រី ÷ ០៤នាក់
  - ចំនួនប្រពន្ធមន្ត្រីរាជការ ÷ ១៣ នាក់
  - ចំនួនកូន ÷ ២២ នាក់
  - អវត្តមាន ÷ គ្មាន
  - ចំនួនមន្ត្រីរាជការដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ÷ គ្មាន
  - ចំនួនមន្ត្រីរាជការផ្ទេរចូល ÷ ០០ នាក់
  - ចំនួនមន្ត្រីរាជការផ្ទេរចេញ ÷ គ្មាន
  - ចំនួនមន្ត្រីរាជការក្របខ័ណ្ឌថ្មី ÷ ០០ នាក់

- ចំនួនមន្ត្រីរាជការបានតំឡើងប្រាក់បំណាច់មុខងារ ÷ ១៧នាក់
- ចំនួនមន្ត្រីរាជការបានតំឡើងឋានៈ ÷ ២២នាក់
- ចំនួនមន្ត្រីរាជការចូលនិវត្តន៍ ÷ គ្មាន
- ចំនួនបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកបណ្តែត ÷ គ្មាន
- ចំនួនមន្ត្រីរាជការដែលទៅបំពេញបេសកកម្មនៅបរទេស ÷ គ្មាន
- ចំនួនមន្ត្រីរាជការសហការ ជាមួយកម្មវិធី និងជាដៃគូអង្គការនានា ÷ ០៧ នាក់

| ល.រ | នាម និងគោត្តនាម | ភេទ | មុខងារ | សហការជាមួយអង្គការ ឬកម្មវិធី |
|---|---|---|---|---|
| ១ | សេង សារី | ប | ប្រធានមន្ទីរ | -គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ២ | ម៉ប់ ធីរិត | ប | អនុប្រធានមន្ទីរ | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៣ | ឈុន ប៊ុនថេង | ប | ប្រធានការិយាល័យ | គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម(ADB) |
| ៤ | ញាណ គង់ | ប | មន្ត្រី | - គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទាន បន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៥ | ឃិត សុធារ៉ា | ប | មន្ត្រី | គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម(ADB) |
| ៦ | ឌុល ប៉ូលីន | ប | មន្ត្រី | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៧ | ឆាយ សុវណ្ណា | ស | មន្ត្រី | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |

### 1.2. **ការងារលិខិតចេញ-ចូល**

បានធ្វើចរាចរលិខិតស្នាម ក្នុងនោះមាន÷

- មន្ទីរបានចេញលិខិតបេសកកម្ម ចំនួន ១២ ច្បាប់
- មន្ទីរបានចេញលិខិតបេសកកម្មចំនួន ២៣ ច្បាប់
- មន្ទីរបានចេញលិខិតទៅស្ថាប័ននានា និងក្នុងមន្ទីរចំនួន ១៦ ច្បាប់
- បានទទួលលិខិតចូលពីគ្រប់ស្ថាប័ននានា ចំនួន ៤៦ ច្បាប់
- លិខិតផ្សេងៗចំនួន ០៥ ច្បាប់

### 1.3. **ការងាររដ្ឋបាល និងបុគ្គលិក**

- បានរៀបចំលិខិតអនុញ្ញាតិច្បាប់ឈប់សម្រាកជូនមន្ត្រីរាជការចំនួន ០០ ច្បាប់

- បានចូលរួមប្រជុំក្រៅខេត្តចំនួន ០៣ លើក
- បានចូលរួមប្រជុំក្នុងខេត្តចំនួន ០៨ លើក
- បានចូលរួមប្រជុំផ្ទៃក្នុងមន្ទីរចំនួន ០១ លើក

1.4. **ការងារបៀវត្ស និងពលកម្ម**

- កំពុងរៀបចំបៀវត្សជូនមន្ត្រីរាជការថ្នាក់មន្ទីរប្រចាំខែវិច្ឆិកា។

2. **ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ**

❖ ប្រភពថវិការដ្ឋផ្តល់

**+ថវិកាអនុម័តឆ្នាំ២០១៤ = ៤៤៨.២០០.០០០៛០០**

- ប្រាក់ជំពូក ៦០ = ៤០.៥០០.០០០៛០០
- ប្រាក់ជំពូក ៦១ = ១០៥.៥០០.០០០៛០០
- ប្រាក់ជំពូក ៦២ = ៦៥.៥០០.០០០៛០០
- ប្រាក់ជំពូក ៦៤ = ២៣៦.៤០០.០០០៛០០
- ប្រាក់ជំពូក ៦៣ = ៣០០.០០០៛០០

**+ ថវិកាចំណាយសម្រាប់ខែវិច្ឆិកា ឆ្នាំ២០១៤ = ២៣.៤៧៩.៩៤០៛០០**

- ប្រាក់ជំពូក ៦0 = ០០៛០០
- ប្រាក់ជំពូក ៦១ = ០០៛០០
- ប្រាក់ជំពូក ៦២ = ០០៛០០
- ប្រាក់ជំពូក ៦៤ = ០០៛០០
- ប្រាក់ជំពូក ៦៣ = ១៤.៧៧៥.៩៦០៛០០
- បានបើកប្រាក់បៀវត្សមន្ត្រីរាជការតាម ATM សម្រាប់ខែតុលា ឆ្នាំ ២០១៤
- ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៤ ចូលរួមសិក្ខាសាលា ស្តីពីការពង្រឹងសមត្ថភាពថវិកាកម្មវិធី របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅខេត្តព្រះស៊ីហនុ
- ថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០១៤ បានទៅទំនាក់ទំនងការងារជាមួយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ នៅក្រសួងអភិវឌ្ឍន៍ជនបទ
- បើកឯកសារសម្រាប់ផ្គត់ផ្គង់សម្ភារៈបរិក្ខារនៅអង្គភាពលទ្ធកម្មសាលាខេត្តធ្វើសំណើសុំនិយ័តភាពថវិកាផ្ទៃក្នុងជំពូក ៦៤ រត់ការដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានធ្វើផែនការលទ្ធកម្មសម្រាប់ចំណាយថវិកាឆ្នាំ២០១៥ ជូនអង្គភាពលទ្ធកម្មសាលាខេត្ត។

3. **ការងារផែនការ និងស្ថិតិ ÷**

- ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានធ្វើរបាយការណ៍ផែនការឆ្នាំ ២០១៥ ដាក់ជូននាយកដ្ឋានផែនការ និងស្ថិតិ នៃក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានធ្វើរបាយការណ៍ផែនការឆ្នាំ ២០១៥ - ២០១៩ ដាក់ជូនមន្ទីរផែនការខេត្ត។

4. **ការងារអធិការកិច្ច និង សវនកម្ម÷**
   - ថ្ងៃទី ១១ - ១៥ ខែវិច្ឆិកា ឆ្នាំ ២០១៤ ក្រុមអគារធិការកិច្ចក្រសួងអភិវឌ្ឍន៍ជនបទ បានចុះមកពិនិត្យចំណូល-ចំណាយថវិកា ឆ្នាំ២០១៣។

5. **ការងារទំនាក់ទំនងសាធារណៈ**:
   - ថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៤ បានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ ក្រោមអធិបតីភាព ឯកឧត្តម យ៉ុង គឹមហ៊ាង នៅសាលាស្រុកសង្គមថ្មី ដែលមានអ្នកចូលរួមសរុប១៧/២២នាក់ ក្នុងនោះស្រី០៩នាក់
   - ថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានចូលរួមក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្តអណ្តត្តិទី២ឆ្នាំ២០១៤ នៅសាលាស្រុកសង្គមថ្មី
   - ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានចូលរួមកិច្ចប្រជុំលើកទី ០៤ ប្រចាំខែវិច្ឆិកា ឆ្នាំ ២០១៤ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាខេត្ត ក្រោមអធិបតីភាពលោកជំទាវ ខូយ ប៊ុនថាន ប្រធានគណៈកម្មាធិការ គ.ក.ស.ក នៅសាលប្រជុំសាលាខេត្ត។

II. **សកម្មភាពការងារតាមវិស័យ ÷**

1. **សកម្មភាពផ្លូវជនបទ ÷**
   - ❖ ក្រុមការងាររៀបចំបញ្ជីសារពើភ័ណ្ឌនិងមូលដ្ឋានទិន្នន័យផ្លូវជនបទថ្នាក់ខេត្តបានចុះស្រង់ទិន្នន័យផ្លូវលំជនបទ ទទួលបាន លទ្ធផលដូចខាងក្រោម ÷
   - ផ្លូវប្រភេទលេខ០១ ចំនួន ០៣ខ្សែ ប្រវែង ៨៤.១ គីឡូម៉ែត្រ
   - ផ្លូវប្រភេទលេខ០២ ចំនួន ១៣ខ្សែ ប្រវែង ២៥៧.៩ គីឡូម៉ែត្រ
   - ផ្លូវប្រភេទលេខ០៣ ចំនួន ៣៦ខ្សែ ប្រវែង ៣៨១.៣ គីឡូម៉ែត្រ
   - ផ្លូវប្រភេទលេខ០៤ ចំនួន ៣១៨ខ្សែ ប្រវែង ៨៣.៤៧៥ គីឡូម៉ែត្រ
   - ធ្វើការថែទាំជាលក្ខណៈខួបផ្លូវក្រាលគ្រួសក្រហមចំនួន ០៣ខ្សែ ប្រវែង ២១.២១៣ម៉ែត្រ និងលូចំនួន ១៤ កន្លែងសម្រេចបាន ៧៥% ស្ថិតនៅឃុំយាង និងឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ គម្រោងឆ្នាំ ២០១៤

- ការងារគម្រោងជួសជុលបន្ទាន់ផ្លូវប្រវែង ២ ០០០ ម៉ែត្រ សម្រេចបាន ១០០ % ស្ថិតនៅឃុំគូលែនជើង ស្រុកគូលែន ខេត្តព្រះវិហារ ដែលបានរងការខូចខាតធ្ងន់ធ្ងរដោយជំនន់ទឹកភ្លៀងឆ្នាំ ២០១៤ នេះ
- ថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ បានចូលរួមប្រជុំផ្សព្វផ្សាយព័ត៌មានអំពីដំណើរការកសាងផែនការ អភិវឌ្ឍន៍ខេត្ត ដោយមានការចូលរួមពីមន្ទីរ-វិស័យ ជុំវិញខេត្ត
- ថ្ងៃទី ១០-១១ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានចុះត្រួតពិនិត្យផ្លូវថែទាំខួបជំហ៊ានទី ០១ ប្រវែង ៧ ០០០ម៉ែត្រ និងជំហ៊ានទី ០២ ប្រវែង ៤ ០០០ម៉ែត្រ នៅឃុំយាង ស្រុកជាំក្សាន្តខេត្តព្រះវិហារ
- ថ្ងៃទី ១២-១៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានចុះត្រួតពិនិត្យផ្លូវជួសជុលបន្ទាន់ជំហ៊ានទី ០១ ប្រវែង ២ ០០០ម៉ែត្រ នៅឃុំគូលែនជើង ស្រុកគូលែន ខេត្តព្រះវិហារ។

**១.២/ សកម្មភាពការងារចុះស្រង់ទិន្នន័យ**

- ប្រភេទលេខ០៣ ចំនួន ០១ខ្សែ ប្រវែង ១១.៤០០ ម៉ែត្រ
- ប្រភេទលេខ០៤ ចំនួន ០១ខ្សែ ប្រវែង ១១.៦០០ ម៉ែត្រ

2. **ការងារផ្គត់ផ្គង់ទឹកជនបទ**

- បានរៀបចំឯកសារទូទាត់សម្រាប់ថវិកា ៤0% ឆ្នាំ ២០១៤ ស្តីពីការសាងសង់អណ្តូងស្នប់ចំនួន ១១អណ្តូងស្ថិតក្នុងឃុំស្រអែម ស្រុកជាំក្សាន្ត ទៅនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ
- បានរៀបចំឯកសារទូទាត់សម្រាប់ថវិកា៦ 0% ឆ្នាំ ២០១៤ ស្តីពីការសាងសង់អណ្តូងស្នប់ចំនួន ១១អណ្តូង និងស្រះសហគមន៍ចំនួន ០១ ស្ថិតក្នុងឃុំស្រអែម និងឃុំកន្ទួត ស្រុកជាំក្សាន្ត ទៅនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ។

3. **ការងារថែទាំសុខភាពជនបទ**

- ថ្ងៃទី ២៩ ខែតុលា ដល់ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានចុះជាមួយតំណាងនាយកដ្ឋានថែទាំសុខភាពជនបទ ដើម្បីពិនិត្យសំភារៈបង្គន់អនាម័យតាមភូមិគោលដៅក្នុងស្រុកទាំង ៤ ស្មើ ៦ ឃុំ ១៥ភូមិ ដែលមានអ្នកចូលរួមសរុប ៤៤៩នាក់ ស្រី ៣០៣នាក់
- បានធ្វើការទូទាត់សម្រាប់ថវិកា ៤0% ឆ្នាំ ២០១៤ ក្នុងការផ្គត់ផ្គង់សំភារៈបង្គន់អនាម័យសម្រាប់ភូមិមរតកតេជោសែន ឃុំរំដោះស្រែ ចំនួន ២៣០បង្គន់ និងភូមិចំបក់សែនជ័យ ឃុំស្រអែម ចំនួន ៩០បង្គន់
- បានធ្វើការទូទាត់សម្រាប់ថវិកា ៦0%ឆ្នាំ ២០១៤ ក្នុងការផ្គត់ផ្គង់សម្ភារៈបង្គន់អនាម័យចំនួន ៤៨០បង្គន់ ក្នុងនោះស្រុកជាំក្សាន្ត ចំនួន ៨០បង្គន់ ស្រុកគូលែន ចំនួន ១០០បង្គន់ ស្រុករវៀង ចំនួន ៦៥បង្គន់ និងស្រុកសង្គមថ្មី ចំនួន ២៣៥បង្គន់។

4. **ការងារបណ្តុះបណ្តាល និង ស្រាវជ្រាវ ÷** មិនបានផ្តល់របាយការណ៍

5. **ការងារអភិវឌ្ឍន៍សហគមន៍÷**
   - ថ្ងៃទី ៣០-៣១ ខែតុលា ឆ្នាំ ២០១៤ លោកអនុប្រធានមន្ទីរទទួលបន្ទុក លោកប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍ និងមន្ត្រី បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាល ស្តីពីសញ្ញាណសន្តិសុខស្បៀង សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្តិ៍ និងបានចែកជូននូវគ្រាប់ពូជដំណាំ ០៥ប្រភេទ (គ្រាប់ស្ពៃ ផ្ទីដូង ត្រកួន ត្រសក់ និងត្រប់) និងសំភារៈសំរាប់ធ្វើជីកំប៉ុស្តិ៍ ០៤មុខ (សម,ចបកាប់,កៅស៊ូគ្រប,និងបង្គី) ដល់ ២០គ្រួសារសហគមន៍ នៅភូមិសែនជ័យ ឃុំស្រអែម ស្រុកជាំក្សាន្ត
   - ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានចែកជូនផ្តល់កូនឈើហូបផ្លែចំរុះ ចំនួន ១០០ដើម និងពូជមាន់ ចំនួន ២៦០ក្បាល ជូនដល់គ្រួសារយោធិន ចំនួន ៥២គ្រួសារ ស្ថិតក្នុងភូមិសែនជ័យ ឃុំស្រអែម និងបានផ្តល់កូនត្រីចំរុះ ៤០០ក្បាល ចំនួន ០២ស្រះស្មើ ០២គ្រួសារ ស្ថិតក្នុងភូមិមរតកតេជោសែន ឃុំរំដោះស្រែ ស្រុកជាំក្សាន្ត។
6. **ការងារសេដ្ឋកិច្ចជនបទ÷** គ្មានសកម្មភាព
7. **ការងារជនជាតិដើមភាគតិច÷**
   - ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីការអនុវត្តយន្តការអន្តរក្រសួងលើការពង្រឹងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច នៅសណ្ឋាគាររតនៈស៊ីធី ខេត្តរតនគិរី។
8. **ការងារយេនឌ័រ ÷** គ្មានសកម្មភាព
9. **ការងារ NGOs÷**
   - ថ្ងៃទី ១៣-១៥ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានចុះទៅសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសស្តីពីទឹកស្អាត និងអនាម័យ របស់ជនបង្គោលទឹកស្អាត និងអនាម័យតាមភូមិគោលដៅរបស់អង្គការទស្សនៈពិភពលោកប្រចាំស្រុកជ័យសែន ដែលមានអ្នកចូលរួមសរុប ១០៦នាក់ ស្រី ៤៣នាក់ កុមារ ២៣នាក់។
10. **គម្រោង / កម្មវិធី ÷**

10.1. **គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញទានបន្ថែម** (ADB)

- ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានចុះត្រួតពិនិត្យផ្លូវក្រាលក្រួសក្រហម០១ខ្សែ ប្រវែង ៨ ៣២២ ម៉ែត្រ និងសំណង់ សិល្បៈការចំនួន ១០កន្លែង លទ្ធផលសម្រេចបាន ÷
  - អង្គភាពសកម្មភាពកំចាត់មីន (CMAC) បានបោសសំអាតមីនបាន ប្រវែង ៦គីឡូម៉ែត្រ លើប្រវែងផ្លូវ ៨ ៣២២ ម៉ែត្រ
  - អ្នកទទួលការឈ្លូសឆាយផ្លូវបានប្រវែង ៤ ០០០ម៉ែត្រ។

10.2. **កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅតាមសាលារៀន និងសហគមន៍ (គាំទ្រថវិកា ដោយ** UNICEF)

- ថ្ងៃទី ១៣-១៤ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានបើកវគ្គបណ្តុះបណ្តាលស្តីពីសហគមន៍ដឹកនាំអនុវត្តអនាម័យទាំងស្រុង(CLTS) មកពី ០៥ភូមិ នៃសង្កាត់ប៉ាលហាល រួមមានភូមិចំការស្រម៉ូវ អូរខ្លែងពរ ហ្វសែត ភារកិច្ច និងភូមិស្វារពរ ឧបត្ថម្ភថវិកាដោយអង្គការ UNICEF ដែលមានអ្នកចូលរួមសរុប ២៩នាក់ ក្នុងនោះស្រី ១៨នាក់
- ថ្ងៃទី ១៧-១៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានបើកវគ្គបណ្តុះបណ្តាលស្តីពីសហគមន៍ដឹកនាំអនុវត្តអនាម័យទាំងស្រុង(CLTS) មកពី ០៥ភូមិ នៃសង្កាត់ប៉ាលហាល រួមមានភូមិភូមិប៉ាលហាល ទំនប់ សាមគ្គី អភិវឌ្ឍន៍ និងភូមិឯកភាព ឧបត្ថម្ភថវិកាដោយអង្គការ UNICEF ដែលមានអ្នកចូលរួមសរុប ២៩នាក់ ក្នុងនោះស្រី ១៥នាក់
- -នៅថ្ងៃទី ២០-២១ ខែវិច្ឆិកា ឆ្នាំ ២០១៤ បានចូលរួមប្រជុំពិនិត្យឡើងវិញ និងរៀបចំផែនការបន្តអនុវត្តកម្មវិធី CLTS, HP, និង កម្មវិធី SC-WASH នៅខេត្តតាកែវ ក្រោមការសម្របសម្រួលពីនាយកដ្ឋានថែទាំសុខភាពជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមការគាំទ្រពីអង្គការ UNICEF ដែលមានអ្នកចូលរួមសរុប ១៧នាក់ ស្ត្រី ៥នាក់។